# ការងារនៅទីក្រុងឡុងប៊ិច




**ហេតុអ្វីត្រូវធ្វើការងារ នៅទីក្រុងឡុងប៊ិច ?**

អាកាសធាតុល្អ ឧទ្យានដែលទទួលបានពានរង្វាន់ ទីប្រជុំជន ដែលជាកន្លែងកំសាន្តដ៏អស្ចារ្យ សហគមន៍ចម្រុះ និងលំនៅឋានដែលមានតម្លៃសមរម្យ គឺជាមូលហេតុ ដែលត្រូវសម្រេចមកបម្រើការងារនៅទីក្រុងឡុងប៊ិច ។ សូមចូលមើលការណែនាំរបស់យើងខ្ញុំ សម្រាប់ទំព័រ អ្នកទស្សនា និង ប្រជាពលរដ្ឋក្នុងមូលដ្ឋាន ។

ទីក្រុងឡុងប៊ិចមាននិយោជិក ជាង 4,730 នាក់ និងមានការងារលើសពី 500 តួនាទី ។ តួនាទីមានចាប់ពី កម្រិតដំបូង រហូតដល់ កម្រិតវិជ្ជាជីវៈ និងជំនាញខ្ពស់ ។ យោងតាមចំនួនតួនាទីដ៏ច្រើនទាំងនេះ និយោជិកមានជម្រើសមាគ៌ាអាជីពការងារ ផ្សេងៗ គ្នាជាច្រើន ។ លើសពីនេះទៅទៀត ទីក្រុងក៏ផ្តល់ការណែនាំ អំពីការងារ ការតម្រង់ផ្លូវ និងការដំឡើងតួនាទី សម្រាប់ការរៀបចំអាជីព ជាមួយទីក្រុងឡុងប៊ិច ។

**តើខ្ញុំដាក់ពាក្យស្នើសុំដោយរបៀបណាដែរ ?**

ការងារជាមួយទីក្រុងឡុងប៊ិចភាគច្រើន គឺជាតួនាទី មានការចាត់ថ្នាក់ ដែលតម្រូវឱ្យលោកអ្នកដាក់ពាក្យនៅក្រសួងសេវាកម្មស៊ីវិល ប្រឡងតេស្តសមត្ថភាព និងធ្វើការជម្រុះសម្រាំង ជាបេក្ខជន ចូលក្នុងបញ្ជីមានអ្នកសិទ្ធិទទួលបាន ។ បន្ទាប់មក ក្រសួងនានានៃទីក្រុងឡុងប៊ិច សម្ភាសបេក្ខជន ដែលជាប់ឈ្មោះក្នុងបញ្ជីអ្នកមានសិទ្ធិទទួលបាន និងជ្រើសរើសបេក្ខជនដ៏ល្អបំផុត ដែលត្រូវតាមតម្រូវការរបស់ក្រសួង ។

1. កំណត់តួនាទីនៅទំនេរណាមួយ ដែលលោកអ្នកនឹងដាក់ពាក្យស្នើសុំ ហើយបំពេញពាក្យស្នើសុំលើអ៊ីនធើណិត ។

2. នៅពេលលោកអ្នកដាក់ពាក្យស្នើសុំ ហើយលោកអ្នកមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដើម្បីធ្វើតេស្តនោះលោកអ្នកនឹងទទួលបានការជូនដំណឹងតាមអ៊ីម៉ែល អំពីកាលបរិច្ឆេទ ម៉ោង និងទីតាំងប្រឡង ។ អាស្រ័យលើការប្រឡង តាមតួនាទី ដំណើរការនេះអាចមានរយៈពេល ពីពីរសប្តាហ៍ ទៅប្រាំមួយសប្តាហ៍ ។ នៅពេលលោកអ្នក បានបញ្ចប់ដំណាក់កាលធ្វើតេស្តរួច លោកអ្នកនឹងទទួលបានការជូនដំណឹង អំពីពិន្ទុនិងការបញ្ចូលទៅក្នុងបញ្ជីអ្នកមានសិទ្ធិទទួលបាន ។ បញ្ជីអ្នកមានសិទ្ធិទទួលបាន មានចំណាត់ថ្នាក់ចាប់ពីក្រុម A ក្រុម B ក្រុម C ។ល។ ហើយលោកអ្នកនឹងត្រូវបញ្ចូល ទៅក្នុងក្រុមណាមួយ អាស្រ័យលើពិន្ទុរបស់លោកអ្នក ។ សូមស្វែងយល់បន្ថែម អំពីដំណាក់កាលធ្វើតេស្ត

3. ក្រសួងនានា ដែលមានតំណែងនៅទំនេរសម្រាប់តួនាទីនេះ នឹងទទួលបានបញ្ជីអ្នកមានសិទ្ធិទទួល

# ការងារនៅទីក្រុងឡុងប៊ិច

បាន ពីសេវាកម្មស៊ីវិល ដែលពួកគេអាចចាប់ផ្តើមការសម្ភាសន៍ជ្រើសរើសរបស់ខ្លួន និងជ្រើសយកបេក្ខជន ដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់ ។ ក្រសួងនានា ទទួលបានបញ្ជីអ្នកមានសិទ្ធិទទួលបាន ដោយចាប់ផ្តើមពី ក្រុម A ជានិច្ច ។ បន្ទាប់ពីជ្រើសរើសបេក្ខជនរួច ក្រុមបន្ទាប់នឹងត្រូវបានផ្តល់ជូន ។

4. បេក្ខជនដែលទទួលបានការងារ នឹងតម្រូវឱ្យឆ្លងកាត់ការត្រួតពិនិត្យប្រវត្តិរូប តាមស្នាមម្រាមដៃ និងការធ្វើតេស្តផ្នែកសុខភាព ក្នុងលក្ខណៈសមស្រប ។ ដំណើរការនេះអាចមានរយៈពេល រហូតដល់ បួនសប្តាហ៍ ។

ទីក្រុងឡុងប៊ិចក៏មានការងារ ដែលមិនតម្រូវឱ្យដាក់ពាក្យស្នើសុំ តាមរយៈក្រសួងសេវាកម្មស៊ីវិល ផងដែរ ។ តួនាទីមិនចាត់ថ្នាក់ទាំងនេះ រួមមានផ្នែកគ្រប់គ្រង ៖ ការងារ បម្រើការ ជូនមន្ត្រីដែលបានបោះឆ្នោតជ្រើសតាំង តួនាទីស្មៀនសម្ងាត់ ឬ ការងារក្រៅម៉ោង តាមដូវកាល ឬ ក្នុងលក្ខណៈបណ្តោះអាសន្ន ។ ជាទូទៅ ក្រសួងដែលធ្វើការជ្រើសរើស មានការងារមិនចាត់ថ្នាក់ ។ ក្រសួងដែលធ្វើការជ្រើសរើស នឹងផ្សព្វផ្សាយតួនាទី ស្នើឱ្យបេក្ខជនផ្ញើប្រវត្តិរូប និងសម្ភាសន៍ដោយខ្លួនឯងផ្ទាល់ ។ ក្រសួងដែលធ្វើការជ្រើសរើស ចាត់ចែងកិច្ចការទំនាក់ទំនង ជាបឋម និងជាលើកចុងក្រោយ អំពីលទ្ធផលនៃការជ្រើសរើស ។

## សូមទំនាក់ទំនងមកយើងខ្ញុំ

**ការប្រឡងធ្វើតេស្ត និងការងារ - សេវាកម្មស៊ីវិល**

គេហទំព័រ
562-570-6202
civilservice@longbeach.gov

សេវាកម្មស៊ីវិល - ជាន់ទី 7
333 W. Ocean Blvd
Long Beach, CA 90802

**លេខទំនាក់ទំនងបន្ទាន់ អំពីការងារ 24 ម៉ោង**

562-570-6201

**ការជ្រើសរើសមន្ត្រីប៉ូលិស**

គេហទំព័រ
562-570-6202
PD_PoliceRecruiter@longbeach.gov

**ការជ្រើសរើសបុគ្គលិកអគ្គិភ័យ**

គេហទំព័រ
562-570-6202

**កម្មសិក្សា និងការបណ្តុះបណ្តាល**

# ការងារនៅទីក្រុងឡុងប៊ិច

គេហទំព័រ
562-570-6060
omar.ramos@longbeach.gov

**ផ្នែកធនធានមនុស្ស**

គេហទំព័រ
562-570-6372
melodi.nantes@longbeach.gov

ផ្នែកធនធានមនុស្ស - ជាន់ទី 13
333 W. Ocean Blvd
Long Beach, CA 90802